**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៣៤ ពណ.កសម.ប្រក

# ប្រកាស
# ស្តីពី
# ការកត់ត្រា កិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ/បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ១ _ គោលបំណង

ប្រកាសនេះមានគោលបំណងលើកកម្ពស់និងពង្រឹង កិច្ចការពារកម្មសិទ្ធិបញ្ញា ការផ្ទេរបច្ចេកវិទ្យា និងជំនាញ ការទាក់ទាញវិនិយោគ ការប្រកបអាជីវកម្ម និងការប្រកួតប្រជែងដោយស្មោះត្រង់ចំពោះទំនិញ និងសេវាក្រោមកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## ប្រការ២ ._ គោលដៅ

ប្រកាសនេះមានគោលដៅ៖

១- កំណត់នីតិវិធីលម្អិត លក្ខខណ្ឌ និងឯកសារតម្រូវ សម្រាប់ការកត់ត្រា និងតម្កល់កិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាអាជ្ញាប័ណ្ណបន្តកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្មនិងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្មបន្ត

២- កំណត់វិសាលភាព សុពលភាព សិទ្ធិ និងកាតព្វកិច្ច នៃការកត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យា អាជ្ញាប័ណ្ណបន្តកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្មនិងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្មបន្ត ឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា

៣- គ្រប់គ្រងការផ្តល់អាជ្ញាប័ណ្ណ ការផ្តល់អាជ្ញាប័ណ្ណបន្ត ការផ្តល់សិទ្ធិប្រកបអាជីវកម្ម និងការផ្តល់សិទ្ធិប្រកបអាជីវកម្មបន្តឱ្យមានប្រសិទ្ធភាព

៤- កំណត់នីតិវិធីដោះស្រាយវិវាទពាក់ព័ន្ធនឹងការកត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាអាជ្ញាប័ណ្ណ បន្តកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្មបន្ត។

## ប្រការ៣ ._ វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តលើការកត់ត្រា និងតម្កល់កិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាអាជ្ញា ប័ណ្ណបន្តកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្មបន្តលើម៉ាកដែលបានចុះបញ្ជី និងម៉ាកដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ៤ ._ និយមន័យ

វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **"ការផ្តល់អាជ្ញាប័ណ្ណ"** សំដៅដល់ការព្រមព្រៀងមួយ ដែលម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅកម្ពុជាអនុញ្ញាតឱ្យបុគ្គលមួយ ឬច្រើនប្រើប្រាស់ម៉ាកនោះដោយយកកម្រៃ ឬមិនយកកម្រៃ និងដោយគោរពតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នារវាងអ្នកផ្តល់អាជ្ញាប័ណ្ណ និងអ្នកទទួលអាជ្ញាប័ណ្ណ

២- **"ការផ្តល់អាជ្ញាប័ណ្ណផ្តាច់មុខ"** សំដៅដល់ទម្រង់មួយនៃការផ្តល់អាជ្ញាប័ណ្ណលើម៉ាកដែលសិទ្ធិប្រើប្រាស់ម៉ាកត្រូវប្រគល់ឱ្យអ្នកទទួលអាជ្ញាប័ណ្ណតែមួយគត់ ហើយក្នុងរយៈពេលសុពលភាពនៃ ការផ្តល់អាជ្ញាប័ណ្ណនោះ អ្នកផ្តល់អាជ្ញាប័ណ្ណគ្មានសិទ្ធិប្រើប្រាស់ម៉ាក និង/ឬ ផ្តល់អាជ្ញាប័ណ្ណលើម៉ាកនោះឱ្យទៅបុគ្គលណាមួយផ្សេងទៀតឡើយ

៣- **"ការផ្តល់អាជ្ញាប័ណ្ណមិនផ្តាច់មុខ"** សំដៅដល់ទម្រង់មួយនៃការផ្តល់អាជ្ញាប័ណ្ណលើម៉ាក ដែលអ្នកផ្តល់អាជ្ញាប័ណ្ណនៅតែមានសិទ្ធិក្នុងការប្រើប្រាស់ម៉ាក និង/ឬផ្តល់អាជ្ញាប័ណ្ណលើម៉ាកឱ្យទៅបុគ្គលផ្សេងទៀតបាន

៤- **"ការផ្តល់អាជ្ញាប័ណ្ណទោល"** សំដៅដល់ទម្រង់មួយនៃការផ្តល់អាជ្ញាប័ណ្ណលើម៉ាក ដែលអ្នកផ្តល់ អាជ្ញាប័ណ្ណផ្តល់សិទ្ធិប្រើប្រាស់ម៉ាកឱ្យទៅអ្នកទទួលអាជ្ញាប័ណ្ណតែមួយ ដោយពុំមានសិទ្ធិផ្តល់អាជ្ញាប័ណ្ណឱ្យទៅបុគ្គលផ្សេងទៀតឡើយ ប៉ុន្តែអ្នកផ្តល់អាជ្ញាប័ណ្ណនៅតែមានសិទ្ធិប្រើប្រាស់ម៉ាកនោះ

៥- **"កិច្ចសន្យាអាជ្ញាប័ណ្ណ"** សំដៅដល់កិច្ចសន្យាមួយដែលម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់អាជ្ញាប័ណ្ណលើម៉ាកនោះឱ្យទៅបុគ្គលណាមួយ។ រាល់កិច្ចសន្យាទាំងឡាយណា ដែលមានចែងទាក់ទងនឹងការផ្តល់អាជ្ញាប័ណ្ណ ប្រើប្រាស់ម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាប់បញ្ចូលជាកិច្ចសន្យាអាជ្ញាប័ណ្ណលើម៉ាកផងដែរ

៦- **"កិច្ចសន្យាអាជ្ញាប័ណ្ណបន្ត"** សំដៅដល់កិច្ចសន្យាមួយ ដែលអ្នកទទួលអាជ្ញាប័ណ្ណប្រើប្រាស់ម៉ាក (ហៅថា "អ្នកផ្ដល់អាជ្ញាប័ណ្ណបន្ត") ប្រគល់សិទ្ធិប្រើប្រាស់ម៉ាកដែលខ្លួនទទួលបាននោះមួយផ្នែក ឬទាំងស្រុងឱ្យទៅបុគ្គលណាមួយផ្សេង (ហៅថា "អ្នកទទួលអាជ្ញាប័ណ្ណបន្ត")

៧- **"កិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្ម"** សំដៅដល់កិច្ចសន្យាមួយ ដែលម្ចាស់អាជីវកម្មបានបង្កើតម៉ូឌែលអាជីវកម្ម អនុញ្ញាតឱ្យបុគ្គលណាមួយប្រើប្រាស់ម៉ូឌែលអាជីវកម្មរបស់ខ្លួន ដោយរួមបញ្ចូលទាំងការប្រើប្រាស់ម៉ាកដែលបានចុះបញ្ជី ឬដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ដំណើរការអាជីវកម្មនោះ ដោយយកកម្រៃ ឬមិនយកកម្រៃ និងដោយគោរពតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា

៨- **"អ្នកផ្ដល់អាជ្ញាប័ណ្ណ"** សំដៅដល់ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រគល់សិទ្ធិប្រើប្រាស់ម៉ាកនោះឱ្យទៅបុគ្គលណាមួយ តាមរយៈការចុះកិច្ចសន្យាអាជ្ញាប័ណ្ណ

៩- **"អ្នកទទួលអាជ្ញាប័ណ្ណ"** សំដៅដល់បុគ្គលដែលទទួលសិទ្ធិប្រើប្រាស់ម៉ាកដែលបានចុះបញ្ជី ឬដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការចុះកិច្ចសន្យា អាជ្ញាប័ណ្ណ

១០- **"អ្នកផ្ដល់សិទ្ធិប្រកបអាជីវកម្ម"** សំដៅដល់ម្ចាស់អាជីវកម្មដែលបានបង្កើតម៉ូឌែលអាជីវកម្មពាក់ម៉ាកដែលបានចុះបញ្ជី ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យបុគ្គលណាមួយប្រើប្រាស់ម៉ូឌែលអាជីវកម្ម និងម៉ាករបស់ខ្លួន តាមរយៈការចុះកិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្ម

១១- **"អ្នកទទួលសិទ្ធិប្រកបអាជីវកម្ម"** សំដៅដល់បុគ្គលដែលទទួលការអនុញ្ញាតឱ្យប្រើប្រាស់ម៉ូឌែលអាជីវកម្ម និងម៉ាកដែលបានចុះបញ្ជី ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការចុះកិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្ម

១២- **"អ្នកផ្ដល់"** សំដៅដល់អ្នកផ្ដល់អាជ្ញាប័ណ្ណ អ្នកផ្ដល់អាជ្ញាប័ណ្ណបន្ត អ្នកផ្ដល់សិទ្ធិប្រកបអាជីវកម្ម ឬអ្នកផ្ដល់សិទ្ធិប្រកបអាជីវកម្មបន្ត

១៣- **"អ្នកទទួល"** សំដៅដល់អ្នកទទួលអាជ្ញាប័ណ្ណ អ្នកទទួលអាជ្ញាប័ណ្ណបន្ត អ្នកទទួលសិទ្ធិប្រកបអាជីវកម្ម ឬអ្នកទទួលសិទ្ធិប្រកបអាជីវកម្មបន្ត

១៤- **"ការផ្ដល់"** សំដៅដល់ការផ្ដល់អាជ្ញាប័ណ្ណ ការផ្ដល់អាជ្ញាប័ណ្ណបន្ត ការផ្ដល់សិទ្ធិប្រកបអាជីវកម្ម ឬការផ្ដល់សិទ្ធិប្រកបអាជីវកម្មបន្ត

១៥- **"កិច្ចសន្យា"** សំដៅដល់កិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាអាជ្ញាប័ណ្ណបន្ត កិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្ម ឬកិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្មបន្ត

១៦- **"ការកត់ត្រា"** សំដៅដល់ការកត់ត្រានិងតម្កល់កិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាអាជ្ញាប័ណ្ណបន្តកិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្ម ឬកិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្មបន្ត ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម

១៧- **"ការបោះពុម្ពផ្សាយ"** សំដៅដល់ការបោះពុម្ពផ្សាយនូវសេចក្ដីសម្រង់ព័ត៌មានពាក់ព័ន្ធនឹងការកត់ត្រា និងតម្កល់កិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាអាជ្ញាប័ណ្ណបន្ត កិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្ម ឬកិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្មបន្តនៅក្នុងព្រឹត្តិបត្រផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម

១៨- **"មន្ត្រីទទួលបន្ទុកកត់ត្រា"** សំដៅដល់មន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដែលទទួលបន្ទុកការកត់ត្រានិងតម្កល់កិច្ចសន្យាអាជ្ញាប័ណ្ណ កិច្ចសន្យាអាជ្ញាប័ណ្ណបន្ត កិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្ម និងកិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្មបន្ត។

## ជំពូកទី ២
## លក្ខខណ្ឌ នីតិវិធី និងឯកសារតម្រូវសម្រាប់ស្នើសុំការកត់ត្រា

### ប្រការ៥ _ លក្ខខណ្ឌតម្រូវទាក់ទងនឹងអ្នកស្នើសុំការកត់ត្រា

ការស្នើសុំកត់ត្រាត្រូវធ្វើឡើងដោយអ្នកផ្តល់ និង/ឬ អ្នកទទួល ឬដោយអ្នកតំណាងស្របច្បាប់របស់អ្នកផ្តល់ និង/ឬ អ្នកទទួល។

### ប្រការ៦ _ លក្ខខណ្ឌតម្រូវទាក់ទងនឹងកិច្ចសន្យា

កិច្ចសន្យាដែលជាកម្មវត្ថុនៃការស្នើសុំកត់ត្រាត្រូវបញ្ជាក់ខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

១- អត្តសញ្ញាណរបស់អ្នកផ្តល់ និងអ្នកទទួល រួមមាន៖
  - ឈ្មោះ សញ្ជាតិ និងអាសយដ្ឋានអចិន្ត្រៃយ៍ ក្នុងករណីអ្នកផ្តល់ និងអ្នកទទួលជារូបវន្តបុគ្គល
  - នាមករណ៍ សញ្ជាតិ និងអាសយដ្ឋានទីស្នាក់ការដែលបានចុះបញ្ជី ក្នុងករណីអ្នកផ្តល់ និងអ្នកទទួលជានីតិបុគ្គល

២- ព័ត៌មានលម្អិតអំពីម៉ាក រួមមាន ម៉ាក លេខចុះបញ្ជី ឬលេខដាក់ពាក្យចុះបញ្ជីម៉ាក ជំពូកទំនិញ ឬសេវា និងយថាប្រភេទនៃទំនិញ និង/ឬ សេវាដែលជាកម្មវត្ថុនៃការកត់ត្រា។

៣- ប្រភេទនៃអាជ្ញាប័ណ្ណ ឬសិទ្ធិប្រកបអាជីវកម្មដែលបានផ្តល់តាមរយៈកិច្ចសន្យា៖ ផ្តាច់មុខ មិនផ្តាច់មុខ ទោល ឬបន្ត

៤- រយៈពេលនៃការផ្តល់ ត្រូវកំណត់ឱ្យបានជាក់លាក់ក្នុងកិច្ចសន្យា ឬអាចកំណត់បានដោយ យោងតាមលក្ខខណ្ឌ និងបញ្ញត្តិដែលមានចែងក្នុងកិច្ចសន្យាពាក់ព័ន្ធផ្សេងទៀត

៥- លក្ខខណ្ឌនៃការត្រួតពិនិត្យលើប្រសិទ្ធភាព និងគុណភាពទំនិញ ឬសេវាដែលបានព្រមព្រៀងគ្នារវាងអ្នកផ្តល់និងអ្នកទទួល

៦- ហត្ថលេខារបស់ភាគី និងការបញ្ជាក់ពីភាពត្រឹមត្រូវដោយសារការី ឬអាជ្ញាធរមានសមត្ថកិច្ច។

### ប្រការ៧ _ ពាក្យស្នើសុំកត់ត្រា

១- អ្នកស្នើសុំការកត់ត្រាត្រូវបំពេញតាមគំរូពាក្យស្នើសុំកត់ត្រារបស់ក្រសួងពាណិជ្ជកម្ម

២- ពាក្យស្នើសុំកត់ត្រាត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំការកត់ត្រា ឬដោយអ្នកតំណាងស្របច្បាប់របស់អ្នកស្នើសុំនោះ។ ក្នុងករណីអ្នកស្នើសុំកត់ត្រាជានីតិបុគ្គល ពាក្យស្នើសុំត្រូវចុះហត្ថលេខា និងប្រថាប់ត្រា

៣- ពាក្យស្នើសុំមួយអាចធ្វើឡើងសម្រាប់ការស្នើសុំកត់ត្រាកិច្ចសន្យាមួយលើម៉ាកមួយ ចំពោះទំនិញ ឬសេវាក្នុងមួយ ឬច្រើនជំពូក។

### ប្រការ៨ _ ការដាក់ពាក្យស្នើសុំកត់ត្រា

១- ការដាក់ពាក្យស្នើសុំកត់ត្រាកិច្ចសន្យា ត្រូវធ្វើឡើងក្នុងពេលណាមួយនៃអំឡុងពេល ៦(ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃការចុះកិច្ចសន្យានោះ

២- ពាក្យស្នើសុំកត់ត្រាដែលបានបំពេញ ត្រូវដាក់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យ និងសម្រេច

៣- ការដាក់ពាក្យស្នើសុំកត់ត្រា ត្រូវមានភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម៖
  ក- ច្បាប់ដើម ឬច្បាប់ចម្លងនៃកិច្ចសន្យាដែលមានបញ្ជាក់ភាពត្រឹមត្រូវ ដោយសារការី ឬអាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់ជាធរមាន

ខ- ក្នុងករណីដែលកិច្ចសន្យាទាំងមូល មិនអាចផ្ដល់ជូនមន្ត្រីទទួលបន្ទុកការកត់ត្រាបាន អ្នកស្នើសុំត្រូវផ្ដល់សម្រង់នៃកិច្ចសន្យា ដែលសម្រង់នោះត្រូវមានបញ្ជាក់ខ្លឹមសារសំខាន់ៗ ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ និងត្រូវមានបញ្ជាក់ភាពត្រឹមត្រូវដោយសារការី ឬអាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់ជាធរមាន

គ- ក្នុងករណីកិច្ចសន្យា ឬសម្រង់នៃកិច្ចសន្យាជាភាសាបរទេសក្រៅពីភាសាអង់គ្លេស ត្រូវបកប្រែជាភាសាខ្មែរ ឬអង់គ្លេស និងត្រូវមានការបញ្ជាក់ពីភាពត្រឹមត្រូវតាមច្បាប់ដើមនៃការបកប្រែនោះ

ឃ- លិខិតប្រគល់សិទ្ធិ និងលិខិតប្រគល់សិទ្ធិបន្តច្បាប់ដើម ប្រសិនបើការដាក់ពាក្យស្នើសុំធ្វើឡើងតាមរយៈភ្នាក់ងារតំណាងស្របច្បាប់

ង- ច្បាប់ចម្លងនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាកដើម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី ឬលិខិតទទួលស្គាល់ការដាក់ពាក្យចុះបញ្ជីម៉ាក ក្នុងករណីម៉ាកដែលបានដាក់ពាក្យសុំចុះបញ្ជីរួចរាល់ ប៉ុន្តែមិនទាន់ទទួលបានការចុះបញ្ជីនៅឡើយ

ច- ឯកសារតម្រូវរបស់អ្នកផ្ដល់៖

១- ករណីជារូបវន្តបុគ្គល

- សញ្ជាតិខ្មែរ៖ ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ដោយមានហត្ថលេខា ឬស្នាមមេដៃរបស់សាមីខ្លួន
- សញ្ជាតិបរទេស និងមានទីតាំងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ច្បាប់ចម្លងលិខិតឆ្លងដែន ទិដ្ឋាការដែលមានសុពលភាព និងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីប្រកបអាជីវកម្ម

២- ក្នុងករណីជានីតិបុគ្គល៖ ច្បាប់ចម្លងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម។

ឆ- ឯកសារតម្រូវរបស់អ្នកទទួល៖

១- ក្នុងករណីជារូបវន្តបុគ្គល

- សញ្ជាតិខ្មែរ៖ ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ដោយមានហត្ថលេខា ឬស្នាមមេដៃរបស់សាមីខ្លួន
- សញ្ជាតិបរទេស និងមានទីតាំងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ច្បាប់ចម្លងលិខិតឆ្លងដែន ទិដ្ឋាការដែលមានសុពលភាព និងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីប្រកបអាជីវកម្ម

២- ករណីជានីតិបុគ្គល៖ ច្បាប់ចម្លងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម។ ចំពោះអ្នកផ្ដល់ និងអ្នកទទួលជារូបវន្តបុគ្គល និងនីតិបុគ្គលបរទេស ដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ និង/ឬ ទីតាំងប្រកបអាជីវកម្មនៅក្រៅព្រះរាជាណាចក្រកម្ពុជា មិនតម្រូវឱ្យផ្ដល់ឯកសារដូចមានចែងក្នុងចំណុច (ច) និង (ឆ) ឡើយ។

ជ- បង្កាន់ដៃបង់កម្រៃសេវាសាធារណៈ។

## ប្រការ៩ _ នីតិវិធីនៃការត្រួតពិនិត្យពាក្យស្នើសុំកត់ត្រា

១- ការកត់ត្រាកិច្ចសន្យាអាចធ្វើទៅបាន លុះត្រាតែអ្នកដាក់ពាក្យស្នើសុំបានបំពេញគ្រប់លក្ខខណ្ឌតម្រូវសម្រាប់ស្នើសុំការកត់ត្រា ក្រោមប្រកាសនេះ។

២- ក្នុងករណីម៉ាកដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ការស្នើសុំកត់ត្រាកិច្ចសន្យា នឹងត្រូវយកមកត្រួតពិនិត្យ នៅពេលដែលម៉ាកនោះទទួលបានការចុះបញ្ជីរួច។

៣- ក្រោយពេលទទួលពាក្យស្នើសុំកត់ត្រា មន្ត្រីទទួលបន្ទុកកត់ត្រាត្រូវពិនិត្យមើលពាក្យស្នើសុំនោះឱ្យបានត្រឹមត្រូវតាមគ្រប់លក្ខខណ្ឌតម្រូវសម្រាប់ស្នើសុំការកត់ត្រាក្រោមប្រកាសនេះ។

៤- ក្នុងករណីដែលមន្ត្រីទទួលបន្ទុកកត់ត្រារកឃើញថា លក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំកត់ត្រាណាមួយមិនត្រូវបានបំពេញ ឬពាក្យស្នើសុំកត់ត្រា ឬឯកសារដែលប្រើប្រាស់ភ្ជាប់មកជាមួយពាក្យស្នើសុំមានលក្ខណៈមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ មន្ត្រីទទួលបន្ទុកកត់ត្រាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធបឋមចំពោះការកត់ត្រានោះ ទៅអ្នកដាក់ពាក្យស្នើសុំការកត់ត្រាក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំកត់ត្រា។ ការជូនដំណឹងនេះ ត្រូវបញ្ជាក់ពីព័ត៌មានពាក់ព័ន្ធនឹងមូលហេតុនៃការបដិសេធបឋមនោះ ដោយផ្តល់រយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងដើម្បីតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំការកត់ត្រាបំពេញលក្ខខណ្ឌ និងឆ្លើយតបជាលាយលក្ខណ៍អក្សរទៅមន្ត្រីទទួលបន្ទុកកត់ត្រា។ អ្នកស្នើសុំការកត់ត្រាអាចស្នើសុំពន្យារពេលមិនឱ្យលើស ៦០(ហុកសិប)ថ្ងៃបន្តទៀត សម្រាប់ការឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងករណីមានហេតុផលសមស្រប។

## ប្រការ១០ _ ការបដិសេធពាក្យស្នើសុំកត់ត្រា

១- ប្រសិនបើអ្នកស្នើសុំការកត់ត្រាមិនធ្វើការឆ្លើយតបក្នុងរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ៤ នៃប្រការ ៩ ខាងលើ ពាក្យស្នើសុំកត់ត្រានោះត្រូវបានចាត់ទុកថាបានបោះបង់ចោល

២- មន្ត្រីទទួលបន្ទុកកត់ត្រាត្រូវបដិសេធការស្នើសុំកត់ត្រា ក្នុងករណីរកឃើញថាកិច្ចសន្យាៈ

- ក- មានលក្ខណៈមិនត្រឹមត្រូវតាមទម្រង់ច្បាប់ ឬក្លែងបន្លំ ឬ
- ខ- បណ្តាលឱ្យមានការភ័ន្តច្រឡំដល់សាធារណជន ជាពិសេសចំពោះ ប្រភេទ ប្រភពដើម ដំណើរការផលិតកម្ម ចរិតលក្ខណៈ ភាពសមស្រប នៃទំនិញ ឬសេវាដែលម៉ាកនោះបម្រុងប្រើប្រាស់ ឬកំពុងប្រើប្រាស់ ឬ
- គ- មានលក្ខណៈផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ប្រពៃណីល្អរបស់ជាតិ ឬគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ដូចមានចែងក្នុងកថាខណ្ឌទី២ នៃប្រការនេះ មន្ត្រីទទួលបន្ទុកកត់ត្រាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធចុងក្រោយ នៃការស្នើសុំកត់ត្រាកិច្ចសន្យាទៅអ្នកដាក់ពាក្យស្នើសុំដោយបញ្ជាក់ពីព័ត៌មានពាក់ព័ន្ធនឹងមូលហេតុនៃការបដិសេធនោះ។ សេចក្តីសម្រេចនេះជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្ម ឬទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

## ប្រការ១១ _ ការយល់ព្រមចំពោះការស្នើសុំកត់ត្រា និងការបោះពុម្ពផ្សាយ

១- ប្រសិនបើពិនិត្យឃើញថា ពាក្យស្នើសុំកត់ត្រាកិច្ចសន្យា និងឯកសារភ្ជាប់មកជាមួយពាក្យស្នើសុំនោះបានបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការកត់ត្រា មន្ត្រីទទួលបន្ទុកកត់ត្រាត្រូវធ្វើការកត់ត្រាកិច្ចសន្យានោះ។

២- បន្ទាប់ពីបានកត់ត្រាកិច្ចសន្យារួចហើយ ត្រូវធ្វើការបោះពុម្ពផ្សាយភ្លាមនៅក្នុងព្រឹត្តិបត្រផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានូវសម្រង់ព័ត៌មានជាអាទិ៍ដូចខាងក្រោមៈ

- ក- ឈ្មោះ និងអាសយដ្ឋាន របស់អ្នកផ្តល់ និងអ្នកទទួល
- ខ- គំរូម៉ាក និងលេខចុះបញ្ជីម៉ាក ដែលជាកម្មវត្ថុនៃកិច្ចសន្យា
- គ- ជំពូក និងយថាប្រភេទនៃទំនិញ ឬសេវា ដែលជាកម្មវត្ថុនៃកិច្ចសន្យា
- ឃ- ប្រភេទនៃអាជ្ញាប័ណ្ណ ឬសិទ្ធិប្រកបអាជីវកម្ម
- ង- កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំកត់ត្រា កាលបរិច្ឆេទនៃការកត់ត្រា និងរយៈពេលសុពលភាពនៃការកត់ត្រានោះ

ច- ដែនដីនៃការផ្ដល់អាជ្ញាប័ណ្ណ ឬការផ្ដល់សិទ្ធិប្រកបអាជីវកម្ម

ឆ- ឈ្មោះ និងអាសយដ្ឋាន របស់ភ្នាក់ងារតំណាងរបស់អ្នកស្នើសុំកត់ត្រា (ប្រសិនបើមាន)។

### ប្រការ១២ _ ការស្នើសុំកែតម្រូវពាក្យស្នើសុំកត់ត្រា

១- នៅមុនមានការកត់ត្រាកិច្ចសន្យា អ្នកស្នើសុំកត់ត្រា ឬអ្នកតំណាងស្របច្បាប់អាចធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់មន្ត្រីទទួលបន្ទុកកត់ត្រា ដើម្បីកែតម្រូវផ្នែកណាមួយនៃពាក្យស្នើសុំកត់ត្រាជាពិសេសសេចក្ដីលម្អិតអំពីម៉ាក និងមុខទំនិញ ឬសេវាដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬលក្ខខណ្ឌ ឬការកម្រិតកំណត់នៃការផ្ដល់អាជ្ញាប័ណ្ណ ឬការផ្ដល់សិទ្ធិប្រកបអាជីវកម្មដែលបានព្រមព្រៀងក្នុងកិច្ចសន្យា

២- ការស្នើសុំកែតម្រូវពាក្យស្នើសុំកត់ត្រាកិច្ចសន្យា ត្រូវបំពេញតាមគំរូពាក្យស្នើសុំកែតម្រូវ។ ពាក្យស្នើសុំនេះត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំ ឬដោយអ្នកតំណាងស្របច្បាប់របស់អ្នកស្នើសុំនោះ។ ក្នុងករណីអ្នកស្នើសុំកែតម្រូវពាក្យស្នើសុំកត់ត្រាជានីតិបុគ្គលពាក្យស្នើសុំត្រូវចុះហត្ថលេខា និងប្រថាប់ត្រា

៣- បន្ទាប់ពីមានការស្នើសុំកែតម្រូវពាក្យស្នើសុំកត់ត្រាតាមបញ្ញត្តិនៃប្រការនេះបញ្ញត្តិនៃប្រការ៩១០ និង ១១ នៃប្រកាសនេះត្រូវយកមកអនុវត្ត។

### ប្រការ១៣ _ ការដកពាក្យស្នើសុំកត់ត្រា

នៅមុនមានការកត់ត្រាកិច្ចសន្យា ការដកពាក្យស្នើសុំកត់ត្រាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំកត់ត្រា ឬអ្នកតំណាងស្របច្បាប់របស់អ្នកស្នើសុំនោះ។

## ជំពូកទី ៣
## សុពលភាព សិទ្ធិ និងភារកិច្ច

### ប្រការ១៤ _ សុពលភាពនៃការកត់ត្រា

១- កិច្ចសន្យាណាមួយដែលមិនបានកត់ត្រា នឹងមិនមានអានុភាពចំពោះភាគីទីបីឡើយ

២- ការកត់ត្រាកិច្ចសន្យាត្រូវមានសុពលភាព ៥(ប្រាំ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការកត់ត្រា ឬមានសុពលភាពតិចជាង ៥(ប្រាំ)ឆ្នាំ ដោយយោងតាមសុពលភាពនៃកិច្ចសន្យា និងការចុះបញ្ជីម៉ាក។

### ប្រការ១៥ _ ការបន្តសុពលភាពនៃការកត់ត្រា

១- ការបន្តសុពលភាពនៃការកត់ត្រាអាចធ្វើឡើងសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំម្ដង ដោយគិតចាប់ពីកាលបរិច្ឆេទផុតសុពលភាពនៃការកត់ត្រា

២- សុពលភាពនៃការបន្តការកត់ត្រា ត្រូវយោងតាមសុពលភាពនៃកិច្ចសន្យា និងការចុះបញ្ជីម៉ាក

៣- បុគ្គលដែលមានគោលបំណងបន្តសុពលភាពនៃការកត់ត្រាកិច្ចសន្យា ត្រូវដាក់ពាក្យស្នើសុំក្នុងអំឡុងពេល ៦(ប្រាំមួយ)ខែ មុនកាលបរិច្ឆេទផុតសុពលភាពនៃការកត់ត្រាហើយត្រូវបំពេញតាមនីតិវិធី និងលក្ខខណ្ឌដូចខាងក្រោម៖

ក- ត្រូវបំពេញលក្ខខណ្ឌ និងនីតិវិធី ដូចមានចែងក្នុងជំពូក២ នៃប្រកាសនេះ

ខ- អ្នកដាក់ពាក្យស្នើសុំត្រូវបង់កម្រៃសេវាសាធារណៈដូចបានកំណត់ក្នុងប្រកាសជាធរមាន

គ- ច្បាប់ចម្លងនៃកិច្ចសន្យា និងឯកសារពាក់ព័ន្ធដែលបានតម្កល់រួចហើយ នៅមានសុពលភាពនៅឡើយ។ អ្នកស្នើសុំអាចដាក់ឯកសារពាក់ព័ន្ធបន្ថែម ដើម្បីបន្តសុពលភាពនៃការកត់ត្រា តាមការតម្រូវរបស់មន្ត្រីទទួលបន្ទុកកត់ត្រា

៤- ការបន្តសុពលភាពនៃការកត់ត្រា ត្រូវបោះពុម្ពផ្សាយដូចមានចែងក្នុងប្រការ១១(២)នៃប្រការ នេះ។

## ប្រការ១៦ _ ការបាត់បង់សុពលភាពជាស្វ័យប្រវត្តិ និងការលុបចោលការកត់ត្រា

សុពលភាពនៃការកត់ត្រាកិច្ចសន្យាត្រូវបាត់បង់ជាស្វ័យប្រវត្តិប្រសិនបើ៖

១- សិទ្ធិដែលបានផ្តល់បានដកហូតមកវិញ ឬលុប ដោយហេតុផលណាមួយ ឬ

២- ការបញ្ចប់កិច្ចសន្យាមុនកាលកំណត់ ដោយយោងតាមការកំណត់ជាមុន ឬការព្រមព្រៀងរបស់គូភាគី ឬ

៣- សុពលភាពនៃការចុះបញ្ជីម៉ាកបានបាត់បង់ដោយប្រការណាមួយ ឬ

៤- ម៉ាកដែលបានចុះបញ្ជីត្រូវបានប្តូរម្ចាស់កម្មសិទ្ធិ។

រាល់លក្ខខណ្ឌតម្រូវដូចមានចែងក្នុងចំណុច ១ ដល់ ៤ នៃប្រការនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។ តាមការស្នើសុំពីភាគីដែលពាក់ព័ន្ធ ក្រសួងពាណិជ្ជកម្មត្រូវចេញ សេចក្តីសម្រេចលុបចោលការកត់ត្រាកិច្ចសន្យា ដោយឈរលើមូលហេតុក្នុងចំណុចមួយឬច្រើនខាងលើ ដោយបង់កម្រៃ សេវាសាធារណៈទៅតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការបាត់បង់សុពលភាព និងការលុប ចោលការកត់ត្រានេះ ត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច។

## ប្រការ១៧ _ មោឃភាពនៃការកត់ត្រា

១- ក្រសួងពាណិជ្ជកម្មត្រូវធ្វើមោឃភាពការកត់ត្រាកិច្ចសន្យា ប្រសិនបើរកឃើញថា៖

ក- លក្ខខណ្ឌតម្រូវណាមួយដូចមានចែងក្នុងប្រការ៨ សម្រាប់ស្នើសុំការកត់ត្រាមិនបានបំពេញ ឬ

ខ- កិច្ចសន្យាដែលមិនបានចែងអំពីការត្រួតពិនិត្យដោយប្រសិទ្ធភាពពីសំណាក់អ្នកផ្តល់ ចំពោះគុណភាពទំនិញ ឬសេវារបស់អ្នកទទួល ដែលម៉ាកនោះត្រូវប្រើប្រាស់ ឬ

គ- ការត្រួតពិនិត្យគុណភាពទំនិញ ឬសេវារបស់អ្នកទទួល ដែលម៉ាកត្រូវប្រើប្រាស់ មិនត្រូវបាន អនុវត្តដោយប្រសិទ្ធភាព ឬ

ឃ- កិច្ចសន្យាមានលក្ខណៈណាមួយ ដូចដែលបានរៀបរាប់ក្នុងប្រការ ១០(២) ខាងលើ ឬ

ង- កិច្ចសន្យាមានភាពមិនប្រក្រតីដោយប្រការណាមួយ។

២- បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការកត់ត្រា អាចធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមក នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ឲ្យធ្វើមោឃភាពការកត់ត្រាកិច្ចសន្យាបានប្រសិនបើមាន ភស្តុតាងបង្ហាញអំពីមូលហេតុណាមួយក្នុងកថាខណ្ឌទី១ ខាងលើ

៣- ការធ្វើមោឃភាពការកត់ត្រាកិច្ចសន្យាត្រូវមានអានុភាពអនុវត្ត ចាប់ពីកាលបរិច្ឆេទនៃការកត់ត្រា។

## ប្រការ១៨ _ ការផ្លាស់ប្តូរផ្សេងៗទាក់ទងនឹងការកត់ត្រា

១- មន្ត្រីទទួលបន្ទុកកត់ត្រាត្រូវធ្វើការកត់ត្រា និងបោះពុម្ពផ្សាយជាសាធារណៈក្នុងព្រឹត្តិបត្រផ្លូវការរបស់ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នូវរាល់ការផ្លាស់ប្តូរសំខាន់ៗទាក់ទងនឹងការកត់ត្រាកិច្ចសន្យាដូចខាងក្រោម៖

ក- ការផ្លាស់ប្តូរទៅលើខ្លឹមសារសំខាន់ៗនៃកិច្ចសន្យាដែលត្រូវបានកត់ត្រា ជាពិសេសការផ្លាស់ប្តូរទាក់ ទងនឹងវិសាលភាពនៃការផ្តល់ រយៈពេលនៃកិច្ចសន្យា ម៉ាក មុខទំនិញ ឬសេវាដែលជាកម្មវត្ថុ នៃកិច្ចសន្យានោះ

ខ- ការផ្លាស់ប្តូរទាក់ទងនឹងភាគីនៃកិច្ចសន្យាដែលត្រូវបានកត់ត្រា។

២- អ្នកដាក់ពាក្យស្នើសុំ ឬអ្នកតំណាងស្របច្បាប់របស់អ្នកដាក់ពាក្យស្នើសុំ ត្រូវធ្វើសំណើជាលាយលក្ខណ៍ អក្សរមកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដើម្បីស្នើសុំកត់ត្រាការផ្លាស់ប្តូរផ្សេងៗ ដូចមាន បញ្ជាក់ក្នុងកថាខណ្ឌ១នៃប្រការនេះ។

## ប្រការ១៩ _ ការកែតម្រូវកំហុសបច្ចេកទេស

១- មន្ត្រីទទួលបន្ទុកកត់ត្រាអាចធ្វើការកែប្រែចំណុចណាមួយនៃការកត់ត្រាកិច្ចសន្យា ដោយឆន្ទានុសិទ្ធិបាន ប្រសិនបើរកឃើញថា ការកត់ត្រានោះត្រូវបានធ្វើឡើងដោយមានកំហុសបច្ចេកទេសរបស់មន្ត្រីទទួលបន្ទុកការកត់ត្រា

២- តាមការស្នើសុំ មន្ត្រីទទួលបន្ទុកការកត់ត្រាអាចកែតម្រូវកំហុសបន្តិចបន្តួច ប្រសិនបើការស្នើសុំកែតម្រូវកំហុសនោះមិនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់គូភាគី

៣- រាល់ការកែតម្រូវណាមួយទៅលើកំហុសបច្ចេកទេសទាក់ទងនឹងការកត់ត្រាកិច្ចសន្យា ដោយមន្ត្រីទទួលបន្ទុកការកត់ត្រា ត្រូវធ្វើការជូនដំណឹងទៅអ្នកស្នើសុំការកត់ត្រា ឬអ្នកតំណាងស្របច្បាប់របស់អ្នកស្នើសុំការកត់ត្រានោះ។

## ប្រការ២០ _ សិទ្ធិទទួលបានពីការកត់ត្រា

១- នៅពេលដែលកិច្ចសន្យាត្រូវបានកត់ត្រារួច អ្នកទទួលមានសិទ្ធិអនុវត្តសិទ្ធិលើម៉ាកដែលទទួលបានពីកិច្ចសន្យា

២- ក្នុងកម្រិតដែលអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន អ្នកទទួលមានសិទ្ធិ៖

ក- ដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅកាន់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្នើសុំសេចក្តីសម្រេចបណ្តោះអាសន្ន ឬដាក់ចេញវិធានការតាមមាត់ច្រកព្រំដែន ដើម្បីទប់ស្កាត់ការរំលោភការដែលនឹងមានការរំលោភ ឬទង្វើដែលមិនស្របច្បាប់ដូចមានចែងក្នុងច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិជាធរមាន ព្រមទាំងស្នើឱ្យតុលាការសម្រេចលើសំណងការខូចខាត និងផ្តល់ដំណោះស្រាយផ្សេងៗ ដែលមានចែងក្នុងច្បាប់ជាធរមាន

ខ- ក្នុងករណីដែលអ្នកទទួលបានស្នើសុំទៅអ្នកផ្តល់ឱ្យប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងការរំលោភលើម៉ាក ឬអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ដែលពាក់ព័ន្ធនឹងម៉ាក ប៉ុន្តែអ្នកផ្តល់បានបដិសេធ ឬខកខានមិនបានដាក់ពាក្យបណ្តឹងទេនោះ អ្នកទទួល អាចប្តឹងទៅតុលាការមានសមត្ថកិច្ចដោយផ្ទាល់ តាមនីតិវិធីច្បាប់ជាធរមាន

គ- ក្នុងករណីដែលអ្នកទទួលសំណូមពរទៅអ្នកផ្តល់ឱ្យស្នើសុំអាជ្ញាធរមានសមត្ថកិច្ច ចាត់វិធានការតាមច្បាប់ដើម្បីប្រឆាំងនឹងអំពើរំលោភលើម៉ាក ប៉ុន្តែអ្នកផ្តល់បានបដិសេធ ឬខកខានមិនបានចាត់វិធានការទេនោះ អ្នកទទួលអាចស្នើសុំអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការដោយផ្ទាល់បានក្នុងកម្រិតសិទ្ធិលើម៉ាកដែលខ្លួនបានទទួលតាមរយៈកិច្ចសន្យា

ឃ- ចូលរួមអន្តរាគមន៍ក្នុងបណ្តឹងប្រឆាំងនឹងការរំលោភលើម៉ាក ឬការប្រកួតប្រជែងមិនស្មោះត្រង់ពាក់ព័ន្ធនឹងម៉ាក ដែលផ្តួចផ្តើមដោយម្ចាស់ម៉ាក ឬអ្នកផ្តល់ដើម្បីទាមទារការជួសជុលព្យសនកម្មដែលខ្លួនបានទទួលរង ដោយផ្ទាល់ពីការរំលោភលើម៉ាក ឬការប្រកួតប្រជែងមិនស្មោះត្រង់នោះ។

## ប្រការ២១ . _ ភាតព្វកិច្ចកើតចេញពីការកត់ត្រា

១- តាមការចាំបាច់ អ្នកស្នើសុំការកត់ត្រាអាចចុះផ្សាយលិខិតកត់ត្រាកិច្ចសន្យាក្នុងបណ្តាញសារព័ត៌មានក្នុងប្រទេសកម្ពុជាបន្ទាប់ពីទទួលបាននូវការកត់ត្រា។ អ្នកស្នើសុំការកត់ត្រាអាចបញ្ជូនច្បាប់ចម្លងនៃលិខិតកត់ត្រាកិច្ចសន្យាទៅកាន់ភាគីពាក់ព័ន្ធ ដើម្បីបានជ្រាបជាព័ត៌មាន និងអនុវត្តតាម

២- លិខិតកត់ត្រាកិច្ចសន្យាត្រូវចុះផ្សាយក្នុងព្រឹត្តិបត្រផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

៣- ភាគីពាក់ព័ន្ធទាំងឡាយដែលបាន និងកំពុងធ្វើសកម្មភាពរំលោភទៅលើសិទ្ធិរបស់អ្នកផ្តល់ ឬអ្នកទទួល ឬធ្វើសកម្មភាពដែលមានលក្ខណៈជាការប្រកួតប្រជែងមិនស្មោះត្រង់ ចំពោះការប្រើប្រាស់ម៉ាកដែលជាកម្មវត្ថុនៃកិច្ចសន្យាដែលបានកត់ត្រានៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវបញ្ឈប់ជាបន្ទាន់នូវសកម្មភាពទាំងនោះ គិតចាប់ពីកាលបរិច្ឆេទនៃការកត់ត្រា

៤- អ្នកផ្តល់ត្រូវចាត់វិធានការចាំបាច់ដូចមានចែងក្នុងកិច្ចសន្យា ដើម្បីត្រួតពិនិត្យដោយប្រសិទ្ធភាពចំពោះគុណភាពទំនិញ ឬសេវារបស់អ្នកទទួលដែលប្រើប្រាស់ម៉ាកនោះ។ ការត្រួតពិនិត្យគុណភាពនោះត្រូវធ្វើឡើងជាប្រចាំតាមការកំណត់ក្នុងកិច្ចសន្យាឬដោយមិនបានជូនដំណឹងជាមុន

៥- អ្នកទទួលត្រូវសហការ និងជួយសម្រួលដល់ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពពីសំណាក់ អ្នកផ្តល់ចំពោះគុណភាពទំនិញឬសេវារបស់ខ្លួនដែលប្រើប្រាស់ម៉ាកដែលជាកម្មវត្ថុនៃកិច្ចសន្យា។

## ជំពូកទី ៤
## បណ្តឹងពាក់ព័ន្ធនឹងការកត់ត្រា

### ប្រការ២២ _ សិទ្ធិ និងរយៈពេលនៃការប្តឹងតវ៉ា

១- បុគ្គលណាដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការកត់ត្រាកិច្ចសន្យា មានសិទ្ធិប្តឹងតវ៉ាលើសេចក្តីសម្រេចអំពីការកត់ត្រាទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា ឬតុលាការតាមនីតិវិធីច្បាប់ជាធរមានក្នុង រយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចុះផ្សាយនៃការកត់ត្រា នៅក្នុងព្រឹត្តិបត្រផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

២- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា ជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅតុលាការក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចនោះ។

### ប្រការ២៣ _ ការរំលោភសិទ្ធិលើម៉ាកដែលពាក់ព័ន្ធនឹងការកត់ត្រា និងនីតិវិធីដោះស្រាយវិវាទ

១- អ្នកទទួលដែលបានការកត់ត្រាកិច្ចសន្យារបស់ខ្លួន ឬតំណាងស្របច្បាប់មានសិទ្ធិស្នើសុំអន្តរាគមន៍លើការរំលោភម៉ាក ឬសិទ្ធិប្រើប្រាស់ម៉ាកដែលពាក់ព័ន្ធនឹងកិច្ចសន្យា ពីក្រសួងពាណិជ្ជកម្មដើម្បីចាត់វិធានការដូចខាងក្រោម៖

ក- ចេញលិខិតព្រមានដល់អ្នកដែលរំលោភលើម៉ាកនិងសិទ្ធិប្រើប្រាស់ម៉ាកដែលខ្លួនទទួលបាន

ខ- ធ្វើជាអ្នកសម្រុះសម្រួលក្នុងការដោះស្រាយវិវាទទាក់ទងនឹងការរំលោភលើម៉ាក និង/ឬសិទ្ធិប្រើប្រាស់ម៉ាកដែលខ្លួនទទួលបាន

២- ក្នុងករណីគ្មានការឯកភាពលើការសម្រុះសម្រួលណាមួយ គូភាគីអាចប្តឹងទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា ឬមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឬតុលាការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ជាធរមាន។

## ជំពូកទី ៥
## កម្រៃសេវាសាធារណៈ

### ប្រការ២៤ _ ការបង់កម្រៃសេវា

១- ការស្នើសុំផ្តល់សេវាផ្សេងៗក្រោមប្រកាសនេះ ត្រូវបង់កម្រៃសេវាសាធារណៈតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន

២- រាល់ការបង់កម្រៃសេវាសាធារណៈក្រោមប្រកាសនេះ មិនអាចដកយកវិញ ឬបង្វែរទៅបង់ខ្ទង់ចំណាយផ្សេងទៀតបានឡើយ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ២៥.- អន្តរប្បញ្ញត្តិ**

រាល់កិច្ចសន្យាដែលនៅមានសុពលភាព និងបានកត់ត្រានិងតម្កល់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មមុនកាលបរិច្ឆេទនៃប្រកាសនេះ អាចស្នើសុំបន្តសុពលភាពតាមការកំណត់នៃ ប្រកាសនេះ។

**ប្រការ២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៧.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ